# របាយការណ៍
# ស្តីពី
# វឌ្ឍនភាពការងារគ្រប់គ្រង និងអភិវឌ្ឍតំបន់ទេសចរណ៍ ប្រវត្តិសាស្ត្រអន្លង់វែងឆ្នាំ២០១៥ និងទិសដៅបន្តឆ្នាំ២០១៦

រៀបរៀងដោយ៖ លេខាធិការដ្ឋានគណៈកម្មការអន្តរក្រសួង ដើម្បីគ្រប់គ្រង
និងអភិវឌ្ឍន៍តំបន់ទេសចរណ៍ប្រវត្តិសាស្ត្រអន្លង់វែង



# មាតិកា

I. **សេចក្តីផ្តើម**....................................................................................................២

II. **វឌ្ឍនភាពការងារគ្រប់គ្រង និងអភិវឌ្ឍតំបន់ទេសចរណ៍ប្រវត្តិសាស្ត្រអន្លង់វែង ឆ្នាំ២០១៥-២០១៦**......៣

II.1 គណៈកម្មការអន្តរក្រសួង......................................................................................៣

II.2 លេខាធិការដ្ឋាននៃគណៈកម្មការអន្តរក្រសួង.......................................................................៤

II.3 មជ្ឈមណ្ឌលឯកសារកម្ពុជា......................................................................................៥

II.4 មន្ទីរទេសចរណ៍ខេត្តឧត្តរមានជ័យ..................................................................................៧

III. **បញ្ហាប្រឈម**....................................................................................................៨

IV. **និសដៅបន្ត**....................................................................................................៩

V. **ឧបសម្ព័ន្ធទី១** : បទដ្ឋានគតិយុត្តិ

VI. **ឧបសម្ព័ន្ធទី២** : ប្លង់នៃគម្រោងជួសជុលផ្ទះប្រជុំ នៅតំបន់ ក៤ "ផ្ទះតាម៉ុក ផ្ទះកណ្តាលលើខ្នងភ្នំដងរែក"

VII. **ឧបសម្ព័ន្ធទី៣** : ប្លង់សាងសង់បញ្ជរព័ត៌មាន នៅតំបន់ ក១ "កន្លែងដុតខ្មោចប៉ុលពត"

VIII. **ឧបសម្ព័ន្ធទី៤** : ប្លង់នៃគម្រោងរៀបចំការតាំងពិព័ណ៌អចិន្ត្រៃយ៍នៅតំបន់ ខ៥ "ផ្ទះតាម៉ុក សារៈមន្ទីរតាម៉ុក"

# I. សេចក្តីផ្តើម

អន្លង់វែង គឺជាតំបន់ចុងក្រោយរបស់របបខ្មែរក្រហម ដែលជារបបមួយ ដែលទទួលខុសត្រូវចំពោះអំពើប្រល័យពូជសាសន៍ ការសម្លាប់រង្គាល និងសោកនាដកម្មទាំងឡាយ ដែលមិនអាចរៀបរាប់អស់នៅក្នុងសង្គមកម្ពុជា។ ប្រជាជនកម្ពុជាប្រមាណ ជិតពីរលាននាក់បានស្លាប់នៅក្នុងរបបខ្មែរក្រហម ហើយរហូតមកដល់ពេលបច្ចុប្បន្ននេះ ប្រទេសកម្ពុជានៅតែតស៊ូជាមួយនឹងលទ្ធផលនៃប្រវត្តិសាស្ត្រនេះ។ ប្រជាជនដែលរស់នៅតំបន់អន្លង់វែងភាគច្រើនជាអតីតកងទ័ព និងជាកម្មាភិបាលខ្មែរក្រហម។

ក្រោមការដឹកនាំដ៏ឈ្លាសវៃ និងប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានធ្វើឱ្យតំបន់អន្លង់វែងទទួលបាននូវសុខសន្តិភាព ស្ថិរភាពសង្គម សន្តិភាពសណ្តាប់ធ្នាប់ពេញលេញ គ្រប់វិស័យមានការរីកចំរើន ក្នុងនោះវិស័យទេសចរណ៍មានការរីកចំរើនគួរឱ្យកត់សំគាល់។ ដើម្បីការពារ និងអភិរក្សតំបន់អន្លង់វែងដែលជាតំបន់ចុងក្រោយនៃរបបខ្មែរក្រហម ទុកជាភស្តុតាងប្រវត្តិសាស្ត្រ និងដើម្បីឱ្យអ្នកជំនាន់បានយល់ដឹង និងបទពិសោធន៍នៅរបបមួយនេះ រាជរដ្ឋាភិបាលបានដាក់ចេញនូវ **អនុក្រិត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០១០ ស្តីពីការកំណត់តំបន់ទេសចរណ៍ប្រវត្តិសាស្ត្រអន្លង់វែង** ដែលនៅក្នុងអនុក្រិត្យនេះបានបែងចែកតំបន់ទេសចរណ៍ប្រវត្តិសាស្ត្រអន្លង់វែងជា ២ ដែលក្នុងនោះរួមមាន៖

**១. តំបន់ "ក"** : ជាតំបន់ដែលស្ថិតនៅក្នុងភូមិសាស្ត្រលើជួរភ្នំដងរែក ដែលមានតំបន់ទេសចរណ៍ប្រវត្តិសាស្ត្រតូចៗចំនួន ០៦ដាច់ដោយឡែកពីគ្នា និងមាន ផ្ទៃដីសរុប ១២៤,៦៣៦ ហិកតា

**២. តំបន់"ខ"** : ជាតំបន់ស្ថិតនៅក្នុងភូមិសាស្ត្រលើខ្ពង់រាប និងជើងភ្នំដងរែក ដែលមានតំបន់ទេសចរណ៍ប្រវត្តិសាស្ត្រ ០៨ដាច់ៗពីគ្នា ដែលមានផ្ទៃដីសរុប ៤៣១,៧៣១ហិកតា។

បន្ទាប់ពីបានចេញនូវអនុក្រិត្យនេះរួចមក រាជរដ្ឋាភិបាលបានចេញនូវសេចក្តីសម្រេច ស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីគ្រប់គ្រង និងអភិវឌ្ឍតំបន់ទេសចរណ៍ប្រវត្តិសាស្ត្រអន្លង់វែង ដែលនៅក្នុងអណត្តិទី៤នេះដោយមានការផ្លាស់ប្តូរនូវសមាសភាព រដ្ឋាភិបាលបានចេញនូវសេចក្តីសម្រេចថ្មី ចំនួន ០៣ ដែលក្នុងនោះរួមមាន៖

១. សេចក្តីសម្រេចលេខ ១៥២ សសរ ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីគ្រប់គ្រង និងអភិវឌ្ឍតំបន់ទេសចរណ៍ប្រវត្តិសាស្ត្រអន្លង់វែង

២. សេចក្តីសម្រេចលេខ ០៦ សសរ ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១៥ ស្តីពីការបន្ថែមសមាសភាពនៃគណៈកម្មការអន្តរក្រសួង ដើម្បីគ្រប់គ្រង និងអភិវឌ្ឍតំបន់ទេសចរណ៍ប្រវត្តិសាស្ត្រអន្លង់វែង

៣. សេចក្តីសម្រេចលេខ ៥៦ សសរ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការតែងតាំងសមាសភាពនៃគណៈកម្មការអន្តរក្រសួង ដើម្បីគ្រប់គ្រង និងអភិវឌ្ឍតំបន់ទេសចរណ៍ប្រវត្តិសាស្ត្រអន្លង់វែង។

# II. វឌ្ឍនភាពការងារគ្រប់គ្រង និងអភិវឌ្ឍតំបន់ទេសចរណ៍ ប្រវត្តិសាស្ត្រអន្លង់វែង ឆ្នាំ២០១៥-២០១៦

## II.1 **គណៈកម្មការអន្តរក្រសួង**

ក្រោយពីបង្កើតគណៈកម្មការអន្តរក្រសួងដើម្បីគ្រប់គ្រង និងអភិវឌ្ឍតំបន់ទេសចរណ៍ប្រវត្តិសាស្ត្រអន្លង់វែង ដែលដឹកនាំដោយ **ឯកឧត្តមរដ្ឋមន្ត្រីក្រសួងទេសចរណ៍** តំបន់អន្លង់វែងបានប្រែក្លាយពីតំបន់ជិតដាមនូវអំពើឧក្រិដ្ឋ ក្លាយជាតំបន់ទេសចរណ៍ប្រវត្តិសាស្ត្រ ដែលទាក់ទាញភ្ញៀវទេសចរជាតិ និងអន្តរជាតិចូលទស្សនាស្វែងយល់ពីតំបន់អន្លង់វែងនេះ ដែលនៅក្នុងឆ្នាំ២០១៥ តំបន់ទេសចរណ៍ប្រវត្តិសាស្ត្រអន្លង់វែងបានទទួលភ្ញៀវទេសចរជាតិចំនួន **៤១.៥៥៦នាក់** កើនឡើង ៧២%ធៀបនឹងឆ្នាំ២០១៤ និងភ្ញៀវទេសចរអន្តរជាតិចំនួន **២៣៩១នាក់** កើនឡើង ៤៩% ធៀបនឹងឆ្នាំ២០១៤។ នៅក្នុងឆ្នាំ២០១៦នេះ គិតត្រឹមខែមេសា តំបន់ទេសចរណ៍ប្រវត្តិសាស្ត្រអន្លង់វែងបានទទួលភ្ញៀវជាតិចំនួន **៣៦.៩៧១នាក់** និងភ្ញៀវទេសចរអន្តរជាតិចំនួន **៤០៥នាក់**។

ដើម្បីរក្សានូវកំណើនភ្ញៀវទេសចរ និងផ្សព្វផ្សាយពីតំបន់អន្លង់វែងនេះទៅកាន់ពិភពលោកឲ្យបានស្គាល់កាន់តែច្បាស់ប្រកបដោយប្រសិទ្ធភាព និងនិរន្តរភាព គណៈកម្មការអន្តរក្រសួងដើម្បីគ្រប់គ្រង និងអភិវឌ្ឍតំបន់ទេសចរណ៍ប្រវត្តិសាស្ត្រអន្លង់វែង បានរៀបចំកិច្ចប្រជុំជាច្រើន ដោយពិភាក្សាលើផែនការអភិវឌ្ឍន៍, អភិរក្ស និងផ្សព្វផ្សាយ ដែលជាលទ្ធផលសេចក្តីសម្រេចចំនួន ០២ ត្រូវបានបង្កើតឡើង រួមមានៈ

១. សេចក្តីសម្រេចលេខ ០២២ សសរ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៥ ស្តីពីការបង្កើតក្រុមការងារជំនាញគណៈកម្មការអន្តរក្រសួង ដើម្បីគ្រប់គ្រង និងអភិវឌ្ឍតំបន់ទេសចរណ៍ប្រវត្តិសាស្ត្រអន្លង់វែង របស់គណៈកម្មការអន្តរក្រសួងដើម្បីគ្រប់គ្រង និងអភិវឌ្ឍតំបន់ទេសចរណ៍ប្រវត្តិសាស្ត្រអន្លង់វែង

២. សេចក្តីសម្រេចលេខ ១២២ សសរ.ឧ/ជ ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០១៤ ស្តីពីការបង្កើតគណៈកម្មការដើម្បីថែរក្សាការពារតំបន់ទេសចរណ៍ប្រវត្តិសាស្ត្រអន្លង់វែង របស់សាលាខេត្តឧត្តរមានជ័យ។

បន្ថែមពីនេះទៀត គណៈកម្មការអន្តរក្រសួង ដើម្បីគ្រប់គ្រង និងអភិវឌ្ឍតំបន់ទេសចរណ៍ប្រវត្តិសាស្ត្រអន្លង់វែង បានរៀបចំនូវកិច្ចប្រជុំបូកសរុបលទ្ធផលការងារ និងទិសដៅអនុវត្តបន្តឆ្នាំ២០១៤-២០១៥ ដែលរៀបចំនៅសណ្ឋាគារសាង៉ាំ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ នាថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១៥ និងបានធ្វើរបាយការណ៍រាយការណ៍ជូន **សម្តេចតេជោនាយករដ្ឋមន្ត្រី** រួចហើយ ដែលក្នុងនោះសម្រេចបាននូវលទ្ធផលដូចខាងក្រោមៈ

១. ឯកភាពតាមសំណើរបស់ ឯកឧត្តម **ស ថាវី** អភិបាលនៃគណៈអភិបាលខេត្តឧត្តរមានជ័យ ក្នុងការបង្កើតក្រុមការងារថ្នាក់ខេត្តមួយ ដើម្បីត្រួតពិនិត្យនិយាមការតំបន់ទេសចរណ៍ប្រវត្តិសាស្ត្រនីមួយៗ តាមអនុក្រឹត្យលេខ ០៣៥ អនក្រ.បក ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១០ របស់រាជរដ្ឋាភិបាលកម្ពុជា

២. ឯកភាពផ្តល់ជូនលោក **ឆាំង យុ** នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា ធ្វើការអភិវឌ្ឍតំបន់ "ក១"(កន្លែងដុតខ្មោចប៉ុលពត), តំបន់ "ក៣" (ផ្ទះតាម៉ុក ផ្ទះកណ្តាលលើភ្នំដងរែក), តំបន់ "ខ១" (កន្លែងដុតខ្មោច សុនសេន) និង តំបន់ "ខ៥" (ផ្ទះតាម៉ុក សារមន្ទីរតាម៉ុក) ដោយរៀបចំសាងសង់ជួសជុលតាមលំនាំដើម ដោយមានផែនការអភិវឌ្ឍច្បាស់លាស់ ដើម្បីលើកសំណើសុំការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី**

៣. ឯកភាពជំរុញការរៀបចំតភ្ជាប់ផ្លូវទៅកាន់តំបន់ទេសចរណ៍ប្រវត្តិសាស្ត្រអន្លង់វែងទាំង១៤ចំណុច (ជួសជុលកំរិតតូច)

៤. ចំពោះការជីកដីយកមកធ្វើផ្លូវព័ទ្ធជុំវិញមាត់បឹងអន្លង់វែង គឺត្រូវមានការឯកភាពពីក្រសួងធនធានទឹក និងឧតុនិយម (មានអនុក្រឹត្យការពារដោយឡែក)

៥. រៀបចំបោះបង្គោលតំបន់ប្រវត្តិសាស្ត្រអន្លង់វែងទាំង១៤ចំណុច ដោយមានដាក់ស្លាកឈ្មោះ ស្លាកសញ្ញាបង្ហាញ ទីតាំងច្បាស់លាស់ (ស្ថិតក្នុងគម្រោងថវិកា ឆ្នាំ២០១៦ របស់ក្រសួងទេសចរណ៍)

៦. ក្រសួងទេសចរណ៍ មជ្ឈមណ្ឌលឯកសារកម្ពុជា និងសាលាខេត្តឧត្តរមានជ័យសហការរៀបចំបើកវគ្គបណ្តុះបណ្តាលមគ្គុទ្ទេសក៏ទេសចរណ៍ក្នុងតំបន់ ដោយប្រើប្រាស់ឯកសណ្ឋានមគ្គុទ្ទេសក៏ក្នុងតំបន់។

## II.2 លេខាធិការដ្ឋាននៃគណៈកម្មការអន្តរក្រសួងអន្លង់វែង

ក្រោយពីទទួលបានការសម្រេចនៅក្នុងកិច្ចប្រជុំអន្តរក្រសួង កាលពីថ្ងៃ០៨ ខែកក្កដា ឆ្នាំ២០១៥ នៅស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យរួចមក លេខាធិការដ្ឋានបានសហការជាមួយសាលាខេត្តឧត្តរមានជ័យ មន្ទីរទេសចរណ៍ខេត្តឧត្តរមានជ័យ មជ្ឈមណ្ឌលឯកសារកម្ពុជា និងស្ថាប័នពាក់ព័ន្ធនានា ចុះសិក្សា ប្រមូលទិន្នន័យ និងរៀបចំកិច្ចប្រជុំថ្នាក់បច្ចេកទេសជាច្រើនដង ដើម្បីជំរុញ និងអនុវត្តតាមសេចក្តីសម្រេចនៃកិច្ចប្រជុំប្រកបដោយប្រសិទ្ធភាព។

ក្រុមការងារលេខាធិការដ្ឋាន បានសិក្សា ប្រមូលទិន្នន័យ និងរៀបចំគម្រោងផែនការអភិវឌ្ឍជាជំហានដំបូង ដែលក្នុងនោះ ក្រុមការងារបានលើកគម្រោងដាំបង្គោលព្រំដី ដើម្បីការពារដីអនុក្រិត្យ និងគម្រោងសាងសង់របងនៅតំបន់សំខាន់ៗដែលមានសក្តានុពលទេសចរណ៍មួយចំនួន ដែលក្នុងនោះរួមមាន៖

### ក. គម្រោងដាំបង្គោលព្រំដី

នៅក្នុងគម្រោងដាំបង្គោលព្រំដីនេះ ក្រុមការងារលេខាធិការដ្ឋានមានគម្រោងរៀបចំដាំបង្គោលព្រំដីនៅក្នុងតំបន់ចំនួន ០៧តំបន់ ដែលក្នុងនោះរួមមាន៖

| ល.រ | ទីកន្លែង | ឯកតា | បរិមាណ | ផ្សេងៗ |
|---|---|---|---|---|
| ១ | តំបន់ "ក៣" ផ្ទះតាម៉ុក និងផ្ទះកណ្តាលលើខ្នងភ្នំដងរែក | បង្គោល | ១៨ | |
| ២ | តំបន់ "ក៤" កន្លែងកែច្នៃគ្រាប់កាំភ្លើងលើភ្នំ២០០ | បង្គោល | ១២ | |
| ៣ | តំបន់ "ក៥" ផ្ទះប៉ុលពត ខៀវសំផន (ក្បាលអន្សោង) ទំហំ ១១៧,០៦ហិកតា | បង្គោល | ១៣៨ | |
| ៤ | តំបន់ "ក៦" ឃ្លាំងដាក់សម្ភារៈជើងភ្នំ | បង្គោល | ១៣ | |
| ៥ | តំបន់ "ខ២" ស្រែគំរូ | បង្គោល | ១៧ | |
| ៦ | តំបន់ "ខ៣" ទីតាំងការដ្ឋានដឹកជញ្ជូនតាម៉ុក | បង្គោល | ៨ | |
| ៧ | តំបន់ "ខ៤" បឹងអន្លង់វែង (ទំហំ ៤១៧ ហិកតា) | បង្គោល | ១៧៣ | |
| | | សរុប | ៣៧៧ | |

**ការងារបច្ចេកទេស**

នៅក្នុងគម្រោងរៀបចំដាំបង្គោលព្រំដីនេះ ក្រុមការងារលេខាធិការដ្ឋានបានសិក្សា និងគិតគូរដល់បច្ចេកទេស និងសំភារៈប្រើប្រាស់ប្រកបដោយប្រសិទ្ធភាព និងនិរន្តរភាព ដែលមានរៀបរាប់ដូចខាងក្រោម៖

- បង្គោលព្រំដីដាំគំលាតពីមួយទៅមួយចំងាយ ៤០ម៉ែត្រ-៥០ម៉ែត្រ តាមស្ថានភាពទីតាំងជាក់ស្តែង
- បង្គោលព្រំដីធ្វើឡើងដោយបេតុងអាម៉េ ដោយប្រើប្រាស់ជើងតាងទំហំ ៦តឹក x ៦តឹក កំរាស់ ១,៥តឹក និងសសរទំហំ ៣តឹក x ៣តឹក កំពស់ ១,៥ ម៉ែត្រ ដោយត្រូវជីកក្នុងដីកំពស់ ១ម៉ែត្រ
- សម្ភារៈក្នុងការប្រើប្រាស់តំឡើងជើងតាង រួមមាន៖
    - ដែកកញ្ច្រែងបាតមុខកាត់ ១២លី និងគំលាតពីមួយទៅមួយ ១,៥តឹក
    - បេតុង កំរិត ២៨ MPA (ឬខ្សាច់ ៣,៥ធុង x ថ្ម(១x២) ៥,៥ធុង x ស៊ីម៉ង់ ១បាវ)
- សម្ភារៈក្នុងការប្រើប្រាស់តំឡើងសសរ រួមមាន៖
    - ដែកសសរ មុខកាត់ ១២លី ចំនួន ៤ដើម
    - ដែកកង មុខកាត់ ៦លី ដែលគំលាតពីមួយទៅមួយប្រវែង ១,២តឹក
    - បេតុង កំរិត ២៨ MPA (ឬខ្សាច់ ៣,៥ធុង x ថ្ម(១x២) ៥,៥ធុង x ស៊ីម៉ង់ ១បាវ)។

### ខ. គម្រោងសាងសង់របង

នៅក្នុងគម្រោងដាំបង្គោលព្រំដីនេះ ក្រុមការងារលេខាធិការដ្ឋានមានគម្រោងរៀបចំដាំបង្គោលព្រំដីនៅក្នុងតំបន់ចំនួន ០៤តំបន់ ដែលក្នុងនោះរួមមាន៖

| ល.រ | ទីកន្លែង | ឯកតា | បរិមាណ | ផ្សេងៗ |
|---|---|---|---|---|
| ១ | តំបន់ ក១ "កន្លែងដុតខ្មោចប៉ុលពត" | ម | ៨៦ | |
| ២ | តំបន់ ក២ "កន្លែងកាត់ទោសប៉ុលពត" | ម | ២៨៨ | |
| ៣ | តំបន់ ខ១ "កន្លែងដុតខ្មោច សុន សេន" | ម | ១០០ | |
| ៤ | តំបន់ ខ៥ "ផ្ទះតាម៉ុក សារៈមន្ទីរតាម៉ុក" | ម | ៥៣១ | |
| | | សរុប | ១.00៥ | |

<u>**ការងារបច្ចេកទេស**</u>

- ប្រើប្រាស់បង្គោលរបងបេតុង ទំហំ 0.១ x 0.១ x ២.២ម ដោយដាំបង្គោលគំលាតពីមួយទៅមួយចំងាយ ១ម៉ែត្រ
- ប្រើប្រាស់លួសបន្លា ដោយវាយជាបួនជាន់ដែលមានគំលាតពីមួយទៅមួយចំងាយ 0,៤ម៉ែត្រ។

## II.3 មជ្ឈមណ្ឌលឯកសារកម្ពុជា

បន្ទាប់ពីទទួលបានការឯកភាពប្រគល់ឲ្យមជ្ឈមណ្ឌលឯកសារកម្ពុជាធ្វើការអភិវឌ្ឍតំបន់ទេសចរណ៍ប្រវត្តិសាស្ត្រអន្លង់វែងតាមសេចក្តីសម្រេចនៃកិច្ចប្រជុំអន្តរក្រសួង នាថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១៦ មជ្ឈមណ្ឌលឯកសារកម្ពុជាបានសហការជាមួយលេខាធិការដ្ឋាននៃគណៈកម្មការអន្តរក្រសួង និងស្ថាប័នពាក់ព័ន្ធ ចុះពិនិត្យ សិក្សា និងរៀបចំផែនការអភិវឌ្ឍតំបន់ទេសចរណ៍ប្រវត្តិសាស្ត្រអន្លង់វែង ដោយសម្រេចបានលទ្ធផលដូចខាងក្រោម៖

### ១. ការងារចងក្រងសៀវភៅប្រវត្តិសាស្ត្រអន្លង់វែង

ដោយបានការគាំទ្រពីក្រសួងទេសចរណ៍ មជ្ឈមណ្ឌលឯកសារកម្ពុជាបានសហការជាមួយលេខាធិការដ្ឋានមន្ទីរទេសចរណ៍ខេត្តឧត្តរមានជ័យ និងស្ថាប័នពាក់ព័ន្ធ ចុះសិក្សាស្រាវជ្រាវ និងចងក្រងបានសៀវភៅប្រវត្តិសាស្ត្រអន្លង់វែង ដែលមានចំណងជើងថា "ប្រវត្តិសាស្ត្រតំបន់អន្លង់វែងកាន់កាប់ចុងក្រោយរបស់ចលនាខ្មែរក្រហម" ដែលបច្ចុប្បន្ន

សៀវភៅនេះបានរៀបចំបោះពុម្ពរួចហើយ ដែលមានជាភាសាខ្មែរ និងភាសាអង់គ្លេស ម្យ៉ាងវិញទៀតមជ្ឈមណ្ឌលឯកសារកម្ពុជានឹងរៀបចំបកប្រែជា ០៦ភាសាបន្ថែមទៀត ដើម្បីផ្សព្វផ្សាយ និងលក់ឲ្យភ្ញៀវទេសចរអន្តរជាតិឲ្យបានទូលំទូលាយបន្ថែមទៀត។

**២. ការងារអភិវឌ្ឍតំបន់ទេសចរណ៍ប្រវត្តិសាស្ត្រអន្លង់វែង**

ជាជំហានដំបូងនៅក្នុងគម្រោងផែនការអភិវឌ្ឍតំបន់ទេសចរណ៍ប្រវត្តិសាស្ត្រអន្លង់វែង មជ្ឈមណ្ឌលឯកសារកម្ពុជាបានធ្វើការអភិវឌ្ឍតំបន់អន្លង់វែងចំនួន ០៣កន្លែង រួមមាន៖ តំបន់ ក១ "កន្លែងដុតខ្មោចប៉ុលពត", តំបន់ ក៣ "ផ្ទះតាម៉ុក ផ្ទះកណ្តាលលើខ្នងភ្នំដងរែក" និងតំបន់ ១៥ "ផ្ទះតាម៉ុក សារមន្ទីរតាម៉ុក" ដែលសម្រេចបានលទ្ធផលដូចខាងក្រោម៖

**ក. ការងារជួសជុលបន្ទប់ប្រជុំនៅតំបន់ ក៣ "ផ្ទះតាម៉ុក ផ្ទះកណ្តាលលើខ្នងភ្នំដងរែក" :**

គម្រោងការជួសជុលនេះបានចាប់ផ្តើមចុះសិក្សា និងប្រមូលទិន្នន័យ នៅក្នុងអំឡុងខែតុលា ឆ្នាំ២០១៥ ក្នុងគោលបំណងរៀបចំជួសជុលអគារប្រជុំនេះតាមលំនាំប្លង់ដើម និងវត្ថុធាតុដើមតែមួយ ដោយមជ្ឈមណ្ឌលឯកសារកម្ពុជាសម្រេចបានលទ្ធផលដូចខាងក្រោម៖

- បានរៀបចំប្លង់អគារដែលនៅសេសសល់
- បានរៀបចំប្លង់មេនៃអគារបន្ទប់ប្រជុំ
- បានរៀបចំប្លង់លំអិតនិមួយៗនៃអគារសម្រាប់សាងសង់ឡើងវិញ
- បានរៀបចំប្លង់ 3D នៃអគារបន្ទប់ប្រជុំទាំងមូល
- បានប្រមូលនូវទិន្នន័យនៃសម្ភារៈ និងវត្ថុធាតុដើមសម្រាប់ប្រើប្រាស់ក្នុងការជួសជុល ប៉ុន្តែសម្ភារៈមួយចំនួនមិនអាចរកបាន ដោយមិនមានលក់ក្នុងទីផ្សារ (ហួសសម័យកាល)
- បានរៀបចំបច្ចេកទេសក្នុងការសាងសង់អគារឲ្យតាមលំនាំប្លង់ចាស់។

អគារបន្ទប់ប្រជុំនេះ បានជួសជុលហើយនៅខែមេសា ឆ្នាំ២០១៦ ដែលអគារមានទំហំ ៧,៥ម៉ែត្រ x ១២ម៉ែត្រ និងមានលក្ខណៈដូចខាងក្រោម៖

**ផ្នែកបន្ទប់ប្រជុំ៖**

- ជញ្ជាំង: រៀបឥដ្ឋ និងលាបថ្នាំស្តេត្រូសំអាត
- កំរាលបាតក្រាលរនាបឈើ
- បង្អួចមានដាក់សំណាញ់ដែក និងកញ្ចក់
- ដំបូលប្រក់ក្បឿង និងមានទ្វារចេញចូល។

**ផ្នែកបន្ទប់ទឹក**

- ជញ្ជាំងចាស់ជួសជុលនិង រៀបឥដ្ឋបន្ថែម ដោយលាបថ្នាំស្តេត្រូសំអាត
- ជញ្ជាំងបន្ទប់ទឹកតំលើងដោយប្រើឈើ
- ដំបូលប្រក់សង្ក័សី និងកំរាលបាតចាក់សាបបេតុងឡប់ឡែ
- និងបំពាក់សម្ភារៈប្រើប្រាស់ក្នុងបន្ទប់ទឹក។

**ខ. ការសាងសង់បញ្ជរព័ត៌មាន**

ការសាងសង់បញ្ជរព័ត៌មាននេះ រៀបចំឡើងនៅទីតាំងតំបន់ ក "កន្លែងដុតខ្មោចប៉ុលពត" ដើម្បីផ្សព្វផ្សាយ និងផ្តល់ព័ត៌មានពិត និងច្បាស់លាស់ពីតំបន់នីមួយៗនៃតំបន់ទេសចរណ៍ប្រវត្តិសាស្ត្រអន្លង់វែងទាំង ១៤ចំណុច។

បញ្ជរព័ត៌មាននេះមានទំហំ ០៣ម៉ែត្រ x ០៣ម៉ែត្រ ដែលមានទ្រង់ទ្រាយលក្ខណៈដូចខាងក្រោម៖

- បញ្ជរនេះធ្វើឡើងផុតពីកំពស់ ៤តឹក ដោយធ្វើជណ្ដើរឡើង និងមានកំពស់សរុប ៤,៣៥០ម៉ែត្រ
- បញ្ជរនេះមានជញ្ជាំង និងកំរាលបាតធ្វើអំពីឈើ
- មានទ្វារចូល និងបង្អួច ដែលបង្អួចរៀបចំជា Counter សម្រាប់សួរព័ត៌មាន
- និងដំបូលប្រក់ក្បឿង។

(*សំគាល់: មានគោរពជូនភ្ជាប់នូវឯកសារលម្អិតក្នុងឧបសម្ព័ន្ធទី៣)

**គ. ការងារដាក់ប៉ាណូផ្សព្វផ្សាយ**

- បានរៀបចំដាក់ស្លាកប៉ាណូផែនទីនៃតំបន់ទេសចរណ៍ប្រវត្តិសាស្ត្រអន្លង់វែងទាំង១៤ចំណុច បានចំនួន ០៣ កន្លែង ដែល ក្នុងនោះរួមមាន៖ តំបន់ ក១ "កន្លែងដុតខ្មោចប៉ុលពត", តំបន់ ក៣ "ផ្ទះតាម៉ុក ផ្ទះកណ្ដាលលើខ្នងភ្នំដងរែក និងតំបន់ ខ៥ "ផ្ទះតាម៉ុក សារៈមន្ទីរតាម៉ុក"
- បានរៀបចំស្លាកប៉ាណូផ្សព្វផ្សាយពីប្រវត្តិអន្លង់វែង បានចំនួន ០៦ផ្ទាំង។

## II.4 មន្ទីរទេសចរណ៍ខេត្តឧត្តរមានជ័យ

មន្ទីរទេសចរណ៍ខេត្តឧត្តរមានជ័យជាសមាជិកមួយនៅក្នុងគណៈកម្មការអន្តរក្រសួង ដើម្បីគ្រប់គ្រង និងអភិវឌ្ឍតំបន់ទេសចរណ៍ប្រវត្តិសាស្ត្រអន្លង់វែង និងជាសេនាធិការរបស់ក្រសួងទេសចរណ៍ក្នុងការត្រួតពិនិត្យ និងអនុវត្តផែនការអភិវឌ្ឍតំបន់ទេសចរណ៍ប្រវត្តិសាស្ត្រអន្លង់វែង។ ក្រោយពីទទួលបានសេចក្ដីសម្រេចបង្កើតគណៈកម្មការអន្តរក្រសួងអន្លង់វែងមក មន្ទីរទេសចរណ៍បានបំពេញនូវកាតព្វកិច្ចក្នុងការតាមដាន ត្រួតពិនិត្យ អភិរក្ស និងអនុវត្តផែនការអភិវឌ្ឍ ដែលសម្រេចបាន លទ្ធផលដូចខាងក្រោម៖

- បានរៀបចំបោះបង្គោលឈើ, ជួសជុលរបង, ធ្វើស្លាកឈ្មោះចូលរមណីយដ្ឋាន, រៀបចំដាក់ធុងសម្រាម, ចាក់ដីសម្រួលផ្លូវចូលរមណីយដ្ឋាន, ដាក់លូ និងជួសជុលបន្ទប់ទឹកនៅតាមតំបន់មួយចំនួន ប៉ុន្តែបច្ចុប្បន្នត្រូវបានខូចខាត និងបាត់បង់ស្ទើរទាំងអស់ហើយ
- ខែកក្កដា ឆ្នាំ២០១៤ ឯកឧត្តមអភិបាលខេត្ត បានសង់ជណ្ដើរចំនួន ០១កន្លែងនៅក្នុងតំបន់ ខ៥ "ផ្ទះតាម៉ុក សារៈមន្ទីរតាម៉ុក" ដែលត្រូវបានគេលួចបាត់
- ខែវិច្ឆិកា ឆ្នាំ ២០១៤ មន្ទីរបានសហការជាមួយភូមិបាលស្រុកអន្លង់វែង ចុះចុចឧបករណ៍ GPS តាមនិយាមការតំបន់ទេសចរណ៍ប្រវត្តិសាស្ត្របានចំនួន ០៩ កន្លែង
- បានចុះស្រាវជ្រាវស្វែងរកក្រុមជាង និងអ្នកដែលមានទំនាក់ទំនងក្នុងការសាងសង់ការដ្ឋានសំណង់នៃតំបន់ប្រវត្តិសាស្ត្រអន្លង់វែងទាំងអស់ ដើម្បីសិក្សាគូសប្លង់ថ្មីតាមលំនាំប្លង់ដើមឡើងវិញ និងសិក្សាប៉ាន់ស្មានតម្លៃក្នុងការសាងសង់សំណង់នៅតំបន់នីមួយៗ
- បានសំអាត និងកាប់ឆ្ការព្រៃ បានចំនួន ០៤កន្លែង ដើម្បីការពារភ្លើងឆេះព្រៃ
- បានរៀបចំចាក់ដីពង្រីកផ្លូវចូលតំបន់ ខ៥ "ផ្ទះតាម៉ុក សារៈមន្ទីរតាម៉ុក" ចំនួន ៥០ឡាន ដើម្បីសម្រួលក្នុងការធ្វើដំណើររបស់ភ្ញៀវទេសចរ។

## III. បញ្ហាប្រឈម

- នៅតំបន់ ខ១ "កន្លែងដុតខ្មោច សុន សេន" មានប្រជាជនរស់នៅទីកន្លែងនេះ ពុំព្រមចាកចេញដោយចង់បានសំណងចំនួន $៥.០០០ (ប្រាំពាន់ដុល្លារអាមេរិក)
- នៅតំបន់ ខ២ "ស្រែគំរូ" មានប្រជាជនមួយគ្រួសារ (ប្តីឈ្មោះ សែ ឃុត និងប្រពន្ធឈ្មោះ ញិប ម៉ុនរស់) នៅភូមិស្រះឈូក ឃុំត្រពាំងប្រិយ៍ បានកំពុងយកទីកន្លែងនេះជាកម្មសិទ្ធ និងបានដាំដំឡូង ធ្វើស្រែដោយអះអាងថានេះជាកម្មសិទ្ធរបស់ខ្លួន តាំងពីសមាហរណកម្មជាយូរយារមកហើយ
- នៅក្នុងតំបន់ ខ៤ "បឹងអន្លង់វែង" មានប្រជាជន ៣៧ គ្រួសារអាស្រ័យផលដោយធ្វើស្រែប្រាំងនៅតាមមាត់បឹងអន្លង់វែង ប្រមាណ២៥ ហិកតា (មានកិច្ចសន្យាពីការិយាល័យកសិកម្មស្រុក)
- នៅក្នុងតំបន់ ក៥ "ផ្ទះប៉ុលពត ផ្ទះខៀវសំផន" (ក្បាលអន្សោង) មានរោងយាមចំនួន ០២ កន្លែង ដែលទាហានកំពុងឈរជើង (វរៈ ៤១៥)
- មានការលួចបង្គោលរបង និងឈើមានតម្លៃ
- នៅតាមតំបន់នីមួយៗ មានព្រៃដុះស៊ុកទ្រុប ដែលអាចបណ្តាលឲ្យមានភ្លើងឆេះព្រៃ
- ផ្លូវចូលតំបន់នីមួយៗ មានសភាពលំបាកធ្វើដំណើរ ជាពិសេសផ្លូវចូលទៅកាន់តំបន់ មួយចំនួនលើភ្នំ ដែលជាប់នឹងតំបន់ ស ខាងភាគីថៃ មិនអនុញ្ញាតឲ្យជួសជុល។

# IV. និសដៅបន្ត

## IV.1 ក្រុមការងារលេខាធិការដ្ឋាន

- ជំរុញ និងសហការរៀបចំប្លង់មេលំអិតសម្រាប់តំបន់នីមួយៗ ស្របតាមស្តង់ដា និងបទដ្ឋានគតិយុត្តិរបស់ក្រសួងទេសចរណ៍
- ជំរុញ និងសហការរៀបចំផែនការអភិវឌ្ឍតំបន់ទេសចរណ៍ប្រវត្តិសាស្រ្តអន្លង់វែង
- ជំរុញគម្រោងផែនការធ្វើរបង និងបោះបង្គោលព្រំដីឲ្យបានឆាប់រហ័ស និងមានប្រសិទ្ធភាព
- ជំរុញ និងសហការរៀបចំបើកវគ្គបណ្តុះបណ្តាលគ្រូបង្គោល និងមគ្គុទ្ទេសក៏នៅក្នុងតំបន់ទេសចរណ៍ប្រវត្តិសាស្រ្តអន្លង់វែង
- ជំរុញ និងសហការជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា និងភាគីពាក់ព័ន្ធ ក្នុងការប្រមូលភស្តុតាងដែលនៅសេសសល់យកមករក្សាទុក ដើម្បីដាក់តាំងបង្ហាញ។

## IV.2 មន្ទីរទេសចរណ៍ខេត្តឧត្តរមានជ័យ

- រៀបចំដាក់ស្លាកឈ្មោះទីតាំងទាង ១៤កន្លែង ជាថ្មីឡើងវិញ ដោយជំនួសស្លាកឈ្មោះដែលបានខូចខាត
- រៀបចំស្នាក់ការការិយាល័យទេសចរណ៍តំបន់ប្រវត្តិសាស្រ្តអន្លង់វែងលើខ្នងភ្នំដងរែក
- រៀបចំសាងសង់បញ្ជរព័ត៌មានទេសចរណ៍នៅក្បែរមាត់ច្រកទ្វារអន្តរជាតិជាំ និងបញ្ជរព័ត៌មានដាច់ដោយឡែកមួយទៀតសម្រាប់តំបន់ទេសចរណ៍ប្រវត្តិសាស្រ្តអន្លង់វែង
- ចូលរួមសហការរៀបចំប្លង់មេលំអិតតាមទីតាំងនីមួយៗ ដើម្បីរៀបចំកែលម្អ សេវាកម្ម និងសោភណ្ឌភាពក្នុងការទាក់ទាញភ្ញៀវទេសចរ
- ចូលរួមសហការរៀបចំ និងចងក្រងឯកសារ ដើម្បីរៀបចំបើកវគ្គបណ្តុះបណ្តាលមគ្គុទ្ទេសក៏ទេសចរណ៍ក្នុងតំបន់ទេសចរណ៍ប្រវត្តិសាស្រ្តអន្លង់វែង។

## IV.3 មជ្ឈមណ្ឌលឯកសារកម្ពុជា

- រៀបចំពិនិត្យមើល និងចងក្រងឯកសារ ដើម្បីរៀបចំនូវមេរៀនសម្រាប់វគ្គបណ្តុះបណ្តាលមគ្គុទ្ទេសក៏
- សហការជាមួយភាគីពាក់ព័ន្ធ ក្នុងការប្រមូលភស្តុតាងផ្សេងៗបន្ថែម ដែលនៅសេសសល់
- សហការរៀបចំប្លង់មេលំអិតនៅតំបន់ ក១ "កន្លែងដុតខ្មោចប៉ុលពត", តំបន់ ក២ "កន្លែងកាត់ទោសប៉ុលពត ", តំបន់ ក៤ "ផ្ទះតាម៉ុក ផ្ទះកណ្តាលលើខ្នងភ្នំដងរែក" និង តំបន់ ខ៥ "ផ្ទះតាម៉ុក សារៈមន្ទីរតាម៉ុក"
- គម្រោងរៀបចំតំបន់ ខ៥ "ផ្ទះតាម៉ុក សារៈមន្ទីរតាម៉ុក" ដែលក្នុងនោះរួមមាន៖
    - រៀបចំដាក់ផ្ទាំងប៉ាណូប្រវត្តិសង្ខេបនៃចលនាខ្មែរក្រហម និងតំបន់អន្លង់វែង
    - រៀបចំដាក់តាំងពិព័ណ៌រូបភាព និងផ្ទាំងព័ត៌មាន ចំនួន ២១ផ្ទាំង
    - រៀបចំដាក់តាំងប្រវត្តិមេដឹកនាំ ចំនួន ១៤រូប។